ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៥

**សូមផ្ញើជូន**

**ឯកឧត្តម នាយឧត្តមសេនីយ៍ ណាត់ថាក់ផុន ណាកផានីត**

**រដ្ឋមន្ត្រីស្តីទីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ**

"ទីក្រុងបាងកក"

ឯកឧត្តម នាយឧត្តមសេនីយ៍ ជាទីរាប់អាន!

ជាការឆ្លើយតបទៅនឹងលិខិតរបស់ឯកឧត្តម ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០២៥ ទាក់ទងនឹងសំណូមពរក្នុងការរៀបចំកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មាធិការព្រំដែនទូទៅ General Border Committee (GBC) នៅក្នុងទីតាំងអព្យាក្រឹតដែលស្ថិតនៅក្នុងប្រទេសម៉ាឡេស៊ី ក្នុងកំឡុងថ្ងៃទី០៤ ដល់ទី០៧ ខែសីហា ឆ្នាំ២០២៥ ក្នុងន័យនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ចូលរួមកិច្ចប្រជុំខាងលើ តាមសំណូមពររបស់ឯកឧត្តម។

ទន្ទឹមនឹងនេះ ដោយប្រទេសម៉ាឡេស៊ី សហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតចិន ជាតួអង្គសំខាន់ក្នុងការសម្របសម្រួល ឱ្យមានកិច្ចព្រមព្រៀងបទឈប់បាញ់រវាងកម្ពុជា-ថៃ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ នៅទីក្រុងពូត្រាយ៉ាយ៉ា ប្រទេសម៉ាឡេស៊ី ដូច្នេះ ខ្ញុំសូមស្នើឱ្យមានតំណាង មកពីប្រទេសទាំងបីខាងលើ ចូលរួមជាអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មាធិការព្រំដែនទូទៅ នេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះប្រទេសម៉ាឡេស៊ី ដែលដើរតួនាទីជាប្រធានប្តូរវេនអាស៊ាន និងជាប្រធានក្រុមអ្នកសង្កេតការណ៍អន្តរជាតិ ព្រមទាំងសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានដើរតួនាទីដ៏សំខាន់នេះ។

ខ្ញុំទន្ទឹងរង់ចាំឱកាសជួបជាមួយឯកឧត្តម និងចូលរួមក្នុងកិច្ចសន្ទនាប្រកបដោយមិត្តភាព និងសហការ សំដៅសម្រេចបាននូវដំណោះស្រាយដោយសន្តិវិធី។

សូម ឯកឧត្តម នាយឧត្តមសេនីយ៍ រដ្ឋមន្ត្រីស្តីទីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ ទទួលនូវការរាប់អានអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

Kingdom of Cambodia
Nation Religion King

*(Unofficial Translations)*

Ministry of National Defence

Phnom Penh, 31 July 2025

**To**
**His Excellency General NATTHAPHON NARKPHANIT,**
**Acting Minister of National Defence of Kingdom of Thailand**
**(Bangkok)**

**Your Excellency,**

In response to your letter dated 31 July 2025, concerning the proposal to conduct the extraordinary meeting of the General Border Committee (GBC) in a neutral location, which is in Malaysia, and the meeting to be conducted over the period between 04 - 07 August 2025. In this regard, it would be my pleasure to lead the senior official delegation to attend the above-mentioned meeting as your proposal.

In light of this, Malaysia, the United States, and the People's Republic of China were key players in mediating the ceasefire agreement between Cambodia and Thailand on 28 July 2025 in Putrajaya, Malaysia; therefore, I would like to propose that representatives from the above three countries participate as observers in this upcoming extraordinary meeting of the General Border Committee.

Taking this opportunity, I would also like to convey my sincere appreciation towards Malaysia, which serves as the rotating Chair of ASEAN and the Chair of the International Observer Team, as well as the United States and the People's Republic of China, which have played this important role.

I look forward to the opportunity to meet with you and engage in a constructive dialogue aimed at achieving a peaceful resolution to the matter.

Please accept, **Your Excellency**, **Acting Minister of National Defence,** the assurances of my sincere consideration.

**Deputy Prime Minister, Minister of National Defence**

**(Signed)**

**General TEA Seiha**